ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

**អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក**

លេខ: ០០៣៩ ដជគ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់បណ្ណសម្គាល់យានជំនិះ ប្រភេទថ្មី

អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក មានកិត្តិយសសូមជម្រាបជូនដល់សាធារណជនទាំងអស់ និងគ្រប់អង្គភាពផ្តល់សេវាសាធារណៈវិស័យដឹកជញ្ជូនផ្លូវគោក មេត្តាជ្រាបថា យោងឧបសម្ព័ន្ធនៃប្រកាសលេខ ១២៣ សក.ប្រក.ដជគ ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៥ ស្តីពីបែបបទ និងនីតិវិធីនៃការចុះបញ្ជីយានជំនិះ ការផ្តល់ផ្លាកលេខសម្គាល់យានជំនិះ និងការលុបយានជំនិះចេញពីបញ្ជីយានជំនិះ អគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោកនៃក្រសួងសាធារណការ និងដឹកជញ្ជូន នឹងដាក់ចេញនូវបណ្ណសម្គាល់យានជំនិះ ប្រភេទថ្មី ដែលបណ្ណសម្គាល់យានជំនិះ ប្រភេទថ្មីនេះ ត្រូវបានធ្វើទំនើបកម្មដោយបំពាក់នូវបច្ចេកវិទ្យាដើម្បីពង្រឹងគុណភាពទប់ស្កាត់ការក្លែងបន្លំ ដែលបង្កឡើងដោយក្រុមបុគ្គលទុច្ចរិតមួយចំនួន។ បណ្ណសម្គាល់យានជំនិះប្រភេទថ្មីនេះ នឹងត្រូវដាក់ឱ្យប្រើប្រាស់ ចាប់ពី**ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៦** នេះតទៅ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ និងគ្រប់អង្គភាពផ្តល់សេវាសាធារណៈវិស័យដឹកជញ្ជូនផ្លូវគោក មេត្តាជ្រាបជាព័ត៌មាន និងជួយផ្សព្វផ្សាយបន្ត ឱ្យមានប្រសិទ្ធភាពខ្ពស់។

ថ្ងៃ អង្គារ ១០រោច ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០២៦

ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ២ ខណ្ឌឫស្សីកែវ ភ្នំពេញ

ទូរស័ព្ទ-ទូរសារៈ (៨៥៥) ២៣ ៤២៦ ៦៤០, (៨៥៥) ២៣ ៤២៧ ៨៦២

# ឧបសម្ព័ន្ធ

## ទម្រង់បណ្ណសម្គាល់យានជំនិះ ប្រភេទថ្មី

ភ្ជាប់សេចក្តីជូនដំណឹងលេខ ០០៣៩ ដជគ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០២៦

១. ទម្រង់បណ្ណសម្គាល់យានជំនិះទោចក្រយានយន្ត ត្រីចក្រយានយន្ត ទោចក្រយានយន្តសណ្តោងរ៉ឺម៉ក និងម៉ូតូកង់បួន

មានរាងចតុកោណកែង មានទំហំ ៥៤មីលីម៉ែត្រ x ៨៥.៥មីលីម៉ែត្រ




២. ទម្រង់បណ្ណសម្គាល់យានជំនិះរថយន្ត រ៉ឺម៉កនិងសឺមីរ៉ឺម៉ក យានយន្តបករណ៍ និងត្រាក់ទ័រនិងយានយន្តកសិកម្មកែច្នៃ

មានរាងចតុកោណកែង មានទំហំ ៥៤មីលីម៉ែត្រ x ៨៥.៥មីលីម៉ែត្រ

